# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ អំពីអំពើឃាតកម្មរកមុខមិនឃើញនៅប្រទេសកម្ពុជា

**Website: www.hoksavann.org**

ថ្ងៃទី១៩ ធ្នូ ២០០៤

កាលពីថ្ងៃសុក្រទី១៧ធ្នូ២០០៤ លោក Robert Hagan នាយកនៃកិច្ចការពលកម្មអន្តរជាតិនៃក្រសួងការបរទេសសហរដ្ឋអាមេរិកបានថ្លែងការណ៍នៅភ្នំពេញក្នុងឱកាសធ្វើទស្សនកិច្ចនៅកម្ពុជា បន្តដាក់សម្ពាធទៅលើរដ្ឋាភិបាលភ្នំពេញ ឲ្យស៊ើបអង្កេតករណីឃាតកម្មរបស់អ្នកដឹកនាំកម្មករដ៏ល្បីល្បាញ គឺលោកជា-វិជ្ជានិងមន្ត្រីសហជីពផ្សេងទៀត ដែលត្រូវគេបាញ់សម្លាប់បន្តបន្ទាប់គ្នា វប្បធម៌គ្មានទោសពៃរ៍នៃប្រទេសកម្ពុជាមិនត្រូវបណ្តែតបណ្តោយឲ្យកើតមានតទៅទៀតទេ ។

ការថ្លែងរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិកនេះ បញ្ជាក់ថាសហរដ្ឋអាមេរិកយកចិត្តទុកដាក់ ចង់ឲ្យប្រទេសកម្ពុជាគោរពសិទ្ធិមនុស្ស បើមានការលួចសម្លាប់គ្នា ត្រូវតែរកមុខឲ្យឃើញ យកមកផ្តន្ទាទោសតាមច្បាប់ ។ តាមការសង្កេត ការលួចសម្លាប់ជាច្រើននាក់ ហើយអ្នកដែលត្រូវគេលួចសម្លាប់ ភាគច្រើនជាសមាជិកគណបក្សប្រឆាំងនឹងរដ្ឋាភិបាល និងជាអ្នកការពារផលប្រយោជន៍ប្រជាពលរដ្ឋ ដែលប៉ះពាល់ផលប្រយោជន៍ជនពុករលួយ ។ សហរដ្ឋអាមេរិកបានអំពាវនាវឲ្យរាជរដ្ឋាភិបាលខ្មែររកមុខឲ្យឃើញអ្នកសម្លាប់លោកជា-វិជ្ជានិងមន្ត្រីសហជីពផ្សេងទៀត យកមកផ្តន្ទាទោស ។ តាមយើងយល់សេចក្តីអំពាវនាវនេះពុំបានទទួលលទ្ធផលទេ ព្រោះតាមគេស្មានថា អ្នកដែលគេប្រើឲ្យទៅសម្លាប់ និងអ្នកដែលស៊ីឈ្នួលសម្លាប់ត្រូវគេសម្លាប់បាត់ទៅហើយ គឺអ្នកដែលប្រើនិងអ្នកដែលជួលនោះ សម្លាប់ដើម្បីបំបិទភស្តុតាង ។ ឧទាហរណ៍ជាក់ស្តែង នៅឆ្នាំ១៩៩៧ ខ្មែរក្រហមម្នាក់ឈ្មោះ ភុន-ភាព ត្រូវ គណបក្សមួយលើកតម្កើងឲ្យនិយាយជាមួយសារពត៌មាន វាយប្រហារគណបក្សមួយទៀត លុះបានសំរេចផលហើយ ទីបំផុតភុន-ភាពត្រូវគេសម្លាប់ ដើម្បីបំបាត់ភស្តុតាង ។ ដូច្នេះសូមធ្វើអនុសាសន៍ អ្នកដែលគេប្រើឲ្យទៅសម្លាប់អ្នកណាម្នាក់ និងអ្នកដែលស៊ីឈ្នួលសម្លាប់អ្នកណាម្នាក់ បើស្រឡាញ់ខ្លួនសូមកុំធ្វើតាមគេប្រើ និងកុំស៊ីឈ្នួលសម្លាប់មនុស្ស ព្រោះខ្លួននឹងត្រូវស្លាប់ដែរ ដោយអ្នកប្រើនិងអ្នកជួលសម្លាប់ ដើម្បីគេបំបិទភស្តុតាង កុំឲ្យមានអ្នកឆ្លើយដាក់គេ ។ នេះជាល្បិចដ៏ជ្រៅរបស់អ្នកដែលចេះតែព្យាបាទគេ ពុំព្រមគោរពតាមច្បាប់ទម្លាប់ឲ្យបានត្រឹមត្រូវ ។ អំពើឃោរឃៅអមនុស្សធម៌នេះ ទោះបីលាក់បិទបាំងយ៉ាងណាក៏ដោយ យូរទៅក៏គង់គេដឹង បើនិយាយតាមព្រះពុទ្ធសាសនាវិញ អំពើបាបដែលបុគ្គលពាលបានប្រព្រឹត្តហើយ នឹងត្រូវទទួលផលបាបវិញក្នុងពេលណាមួយពុំខានលើយ ។ តាំងពីមានអំពើឃាតកម្មមក អាជ្ញាធរខ្មែរពុំដែលរកឃើញឃាតករពិតប្រាកដនិងអ្នកបញ្ជាមកកាត់ទោសឡើយ ។ គេតែងនិយាយថា អំពើឃាតកម្មនេះកើតពីអាជ្ញាធរខ្មែរខ្លួនឯងប្រព្រឹត្ត គេពុំរកឃើញឡើយព្រោះគេពុំស៊ើបអង្កេតតែម្តង ឬបើស៊ើបអង្កេតទៅប៉ះលើថ្នាក់លើ គេឈប់ស៊ើបអង្កេតដែរ ។ បើមានសម្ពាធពីអន្តរជាតិឲ្យស៊ើបអង្កេត គេតៅចាប់មនុស្សដែលមិនបានប្រព្រឹត្តមកកាត់ទោស គឺចាប់មនុស្សរបៀបសិប្បនិមិត្ត ឬចាប់ចោទសមាជិកនៃគណបក្សប្រឆាំងតែម្តង ។ របៀបមួយទៀត គឺគេជួលមនុស្សឲ្យឆ្លើយទទួលសារភាព ។ ចំពោះបញ្ហានេះ បើតុលាការនិងចៅក្រមស៊ើបអង្កេតព្រមទាំងព្រះរាជអាជ្ញាប្រកាន់គោលជំហរយុត្តិធម៌និងឯករាជ្យ គេអាចរកឃើញមេឃាតករនិងអ្នកបញ្ជា ។ ប៉ុន្តែបច្ចុប្បន្ននេះ គេពុំមានសេចក្តីសង្ឃឹមថា តុលាការខ្មែរមានគោលជំហរយុត្តិធម៌និងឯករាជ្យឡើយ បើរឿងរ៉ាវទាក់ទងនឹងផ្លូវនយោបាយ អ្នកដែលត្រូវគេសម្លាប់នោះ ច្រើនជាអ្នកស្នេហាជាតិ ដូចអ្នកខ្លាចបាត់បង់ទឹកដី អ្នកប្រជាធិបតេយ្យ អ្នកប្រឆាំងនឹងអាជ្ញាធរ ដែលរំលោភលើផលប្រយោជន៍ខ្លួនជាប្រជាពលរដ្ឋ ។ គេមានសេចក្តីសង្ស័យថា ហេតុអ្វីបានជាអ្នកស្នេហាជាតិត្រូវគេសម្លាប់ ដូច្នេះមានតែបរទេសចង់បំផ្លាញប្រទេសខ្មែរបញ្ជាពីក្រោយ ហើយខ្មែរខ្លួនឯងជាអ្នកដៃដល់សម្លាប់ជាតិឯង ។ ដំណោះស្រាយមាន ប៉ុន្តែអ្នកកាន់អំណាចខ្មែរពិតជាមិនអនុវត្តឡើយ គឺអាជ្ញាធរខ្មែរដែលទទួលខុសត្រូវរក្សាសន្តិសុខជូនប្រជាពលរដ្ឋ បើពុំមានសមត្ថភាពទប់ស្កាត់កុំឲ្យមានការលួចសម្លាប់គ្នា ហើយបើមានការលួចសម្លាប់ពុំអាចរកអ្នកសម្លាប់ឃើញទេ ត្រូវតែក្លាហានលាចេញពីតំណែង រដ្ឋសភាហៅទៅដេញដោល ហើយដកចេញពីតំណែង ហើយតែងតាំងអ្នកថ្មីដែលមានសមត្ថភាពបំពេញកិច្ចការនេះវិញ ។

ក្នុងរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្ន មិនឲ្យមានទោសប្រហារជីវិត ស្របនឹងពុទ្ធសាសនាមិនឲ្យសម្លាប់ជីវិតមនុស្សសត្វ ប៉ុន្តែនៅមានការលួចសម្លាប់គ្នា ។ ដូច្នេះសូមធ្វើអនុសាសន៍ សូមខ្មែរគ្រប់ឋាន: ទាំងអ្នកកាន់អំណាចទាំងប្រជាពលរដ្ឋ សូមឈប់កាប់សម្លាប់គ្នា ទោះសម្លាប់ដោយចងគំនុំក្តី ដោយការប្លន់ក្តី ដោយផ្លូវនយោបាយក្តី ឬប្រជាពលរដ្ឋសម្លាប់មនុស្សដោយចោទថាជាចោរក្តី ។ ការលួចសម្លាប់គ្នានាំឲ្យប្រជាពលរដ្ឋក្នុងប្រទេសរស់នៅដោយការភិតភ័យ ហើយពួកវិនិយោគទុនពុំហ៊ានមកបណ្តាក់ទុករកស៊ីនៅប្រទេសកម្ពុជាឡើយ ក៏ដូចគ្នានឹងទេសចរបរទេស ក៏ញញើតនឹងមកទស្សនាប្រទេសកម្ពុជាដែរ ការសម្លាប់គ្នានាំឲ្យខ្មែរនិងខ្មែរលែងទុកចិត្តគ្នា ដែលជាហេតុនាំឲ្យបែកសាមគ្គីគ្នា ជាហេតុឲ្យបរទេសមើលងាយ ។ បរទេសដែលឈ្លានពានខ្មែរ ដោយសារខ្មែរបែកសាមគ្គីគ្នា ពុំមានឯកភាពជាតិ ។ ការមិនលួចសម្លាប់គ្នា គឺជាកិត្តិយសដ៏ខ្ពង់ខ្ពស់របស់ជាតិ បើមានបញ្ហាកើតឡើង ត្រូវនាំគ្នាដោះស្រាយដោយសន្តិវិធីនៅក្រោមអំណាចច្បាប់របស់ជាតិនិងច្បាប់អន្តរជាតិ ។៚